**រាជរដ្ឋាភិបាលកម្ពុជា**

**អនុក្រឹត្យ/១៣ អនក្រ.បក/១៩ កុម្ភៈ ១៩៩៨/ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជ រដ្ឋាភិបាល

- បានឃើញ ព្រះរាជក្រមលេខ ន.ស.រកម-០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា

- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត-០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ អនុក្រឹត្យលេខ ២០ អ.ន.ក្រ-ប.ក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

- តាមសំណើរបស់រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ០៨ ខែមករា ឆ្នាំ១៩៩៨

## សំរេច

## ជំពូក១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១:** អនុក្រឹត្យនេះ កំណត់ការរៀបចំបណ្តាអង្គភាពនៃក្រសួងធម្មការ និងសាសនា និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាន និងបណ្តានាយកដ្ឋាននានា។

## ជំពូក២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា២:** ក្រសួងធម្មការ និងសាសនា ត្រូវបានរាជរដ្ឋាភិបាលប្រគល់ បេសកកម្មអោយដឹកនាំ និងគ្រប់ គ្រងវិស័យធម្មការ និងសាសនា នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣:** ក្រសួងធម្មការ និងសាសនា មានមុខការ និងភារកិច្ចដូចតទៅ :

- កំណត់វិធានការដឹកនាំ និងគ្រប់គ្រងអង្គការសាសនាទាំងអស់ ដែលមានទីតាំង និងធ្វើសកម្មភាពនៅ លើទឹកដីកម្ពុជា ដោយយកចិត្តទុកដាក់ជាពិសេស ចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ

- ណែនាំ តាមដាន និងត្រួតពិនិត្យអង្គភាពក្រោមឱវាទ វត្តអារាម វិហារសាសនា មណ្ឌលស្រាវជ្រាវសាសនានានា និងរាល់សមាគមដែលមានចរិតសាសនា អោយប្រតិបត្តិស្របតាមច្បាប់របស់រដ្ឋ និងធម៌ វិន័យសាសនា

- គ្រប់គ្រងការអប់រំ និងការណែនាំពុទ្ធបរិស័ទ និងបរិស័ទ្ធគ្រប់និកាយសាសនាអោយគោរពប្រតិបត្តិតាមក្រឹត្យវិន័យសាសនារៀង១ខ្លួនអោយមានសមគ្គីភាពក្នុងរង្វង់សាសនាខ្លួននិងជាមួយអ្នកកាន់សាសនា ផ្សេង អោយចេះគោរពសិទ្ធិជំនឿសាសនាដទៃ

- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងព្រះសង្ឃ តាមគោលការណ៍ព្រះពុទ្ធសាសនា ដោយសហការជាមួយស្ថាប័ន ពាក់ព័ន្ធ

- កំណត់កម្មវិធីពុទ្ធិកសិក្សា សំដៅបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃ

- ទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធជាមួយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងប្រធានអង្គការ សាសនាក្នុងវិស័យកិច្ចការសាសនា

- ពិនិត្យស្រាវជ្រាវ បកប្រែ ប្រមូល ចងក្រង ថែរក្សា បោះពុម្ព ពង្រឹង ពង្រីក និងផ្សព្វផ្សាយអោយបាន ទូលាយ សៀវភៅ ក្បួនច្បាប់ គម្ពីរដីកា ស្តីអំពីអក្សរសាស្ត្រ វប្បធម៌ ប្រពៃណីពុទ្ធសាសនា ប្រពៃណីជាតិ និងទំនៀមទម្លាប់ ដោយសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- កំណត់វិធានការផ្សព្វផ្សាយធម៌អាថ៌ និងសៀវភៅ-ពត៌មាន ដែលទាក់ទងនឹងវិស័យសាសនា ដោយ សហការជាមួយស្ថាប័នពាក់ព័ន្ធ

- សហប្រតិបត្តិការអន្តរជាតិ ស្តីពីវិស័យសាសនា បទពិសោធន៍ និងអាហារូបករណ៍ ។ រាល់កិច្ចព្រមព្រៀង ត្រូវបានទទួលការយល់ព្រមពីរាជរដ្ឋាភិបាលជាមុន

- រៀបចំ និងចាត់ចែងការប្រព្រឹត្តទៅនៃពុទ្ធិកសិក្សា

- បណ្តុះបណ្តាល និងធ្វើវិក្រិតការគ្រូបង្រៀនពុទ្ធិកសិក្សា

- ធ្វើអធិការកិច្ចគ្រប់វិស័យសាសនា និងវិស័យសាសនសិក្សាធិការ

- ពិនិត្យ អនុញ្ញាតអោយបង្កើត និងបិទសកម្មភាពព្រះវិហារ ឬស្នាក់ការរបស់សាសនានានា

- ពិនិត្យ និងណែនាំការសាងសង់សំណង់សាសនា ព្រះពុទ្ធសាសនា និងការរុះរើ ឬផ្លាស់ប្តូរទីកន្លែង ដោយ សហការជាមួយស្ថាប័នពាក់ព័ន្ធ

- ជំរុញការបង្កើតបណ្ណាល័យនៅតាមវត្តអារាមនានា ក្នុងព្រះរាជាណាចក្រកម្ពុជា សំរាប់ជាប្រយោជន៍ ដល់សាធារណជនទាំងបព្វជិត ទាំងគ្រហស្ថ ។

**មាត្រា៤:** ក្រសួងធម្មការ និងសាសនា មានរចនាសម្ព័ន្ធដូចតទៅ :

ក- នៅថ្នាក់កណ្តាល

- អគ្គនាយកដ្ឋានធម្មការ មាន :

    - នាយកដ្ឋានធម្មការ

    - នាយកដ្ឋានពាហិរសាសនា

    - នាយកដ្ឋានស្រាវជ្រាវ អប់រំ ផ្សព្វផ្សាយធម្មទេសនា

    - នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

    - អធិការដ្ឋានពុទ្ធិកសិក្សា

- ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានឋានៈស្មើនាយកដ្ឋាន

- ពុទ្ធសាសនបណ្ឌិត្យ មានឋានៈស្មើនាយកដ្ឋាន

- អធិការដ្ឋាន

- ខុទ្ទកាល័យរបស់ប្រធានស្ថាប័ន

ខ- អង្គភាពមូលដ្ឋាន

- មន្ទីរធម្មការ និងសាសនា ខេត្ត ក្រុង

អង្គការលេខរបស់ក្រសួងធម្មការ និងសាសនា ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

## ជំពូក៣

## អគ្គនាយកដ្ឋានធម្មការ

**មាត្រា៥:** អគ្គនាយកដ្ឋានធម្មការ ទទួលបន្ទុក :

- ត្រួតពិនិត្យ គ្រប់គ្រង លើវិស័យធម្មការ និងពាហិរសាសនា

- ចាត់ចែងតាមដាន ត្រួតពិនិត្យលើសកម្មភាពទូទៅរបស់នាយកដ្ឋានក្រោមឱវាទ

- សិក្សាលើការងារច្បាប់ ក្នុងក្របខ័ណ្ឌអង្គភាពខ្លួន
និងផ្តល់ជាគំនិតយោបល់ផ្សេងៗជូនប្រធានស្ថាប័ន

- អប់រំផ្សាយការងារធម្មទេសនា

- ធ្វើអធិការកិច្ចបច្ចេកទេសលើវិស័យសាសនា

អគ្គនាយកដ្ឋានធម្មការ ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករង ជាជំនួយការតាមការ ចាំបាច់។

អគ្គនាយកដ្ឋានធម្មការ មាននាយកដ្ឋានចំនួនបី ដូចមានចែងក្នុងមាត្រា ខាងក្រោម ៖

**មាត្រា៦៖** នាយកដ្ឋានធម្មការ ទទួលបន្ទុក ៖

- រៀបចំគ្រប់គ្រងការងារដឹកនាំ និងទុកបំរុងតាមព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ

- អប់រំណែនាំពុទ្ធបរិស័ទ អោយគោរពប្រតិបត្តិធម៌វិន័យត្រឹមត្រូវ

- ទំនាក់ទំនងជាមួយខុទ្ទកាល័យព្រះបរមរាជវាំង អំពីពិធីដែលពាក់ព័ន្ធ

- ទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធ ជាមួយខុទ្ទកាល័យសម្តេចព្រះសង្ឃរាជទាំងពីរគណៈក្នុងវិស័យ សាសនា សំដៅ ៖

* លើកកំពស់កិត្យានុភាពព្រះសង្ឃអោយមានការប្រតិបត្តិធម៌វិន័យម៉ត់ចត់ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត

* លើកឥទ្ធិពលវត្តអារាមជាទីប្រតិបត្តិសាសនា ដែលជាថ្នាលផ្សព្វផ្សាយចំណេះដឹងជាទីរក្សាទុកក្បួនច្បាប់ វប្បធម៌ ប្រពៃណីជាតិ

- លើកយោបល់លើសំណើសុំតែងតាំងមន្ត្រីសង្ឃរាជាគណៈមេគណ អនុគណ ចៅអធិការ សមាជិកថេរ សភា

- រៀបចំទំនាក់ទំនង ធ្វើកិច្ចព្រមព្រៀង និងសហប្រតិបត្តិការអន្តរជាតិខាងវិស័យពុទ្ធសាសនា

- រៀបចំចាត់ចែងបុណ្យប្រពៃណីជាតិ និងប្រពៃណីព្រះពុទ្ធសាសនា

- ពិធីការសាសនាព្រះពុទ្ធ

- ត្រួតពិនិត្យ និងតាមដានរាល់ការសុំធ្វើបុណ្យប្រពៃណីសាសនា

- តាមដានត្រួតពិនិត្យ ណែនាំការសុំសាងសង់សំណង់វត្តអារាម ការរុះរើ ការផ្លាស់ប្តូរទីកន្លែង។

**មាត្រា៧:** នាយកដ្ឋានពាហិរសាសនា ទទួលបន្ទុក :

- ត្រួតពិនិត្យអង្គការសាសនាផ្សេង១ ដែលសុំដាក់ទីតាំង និងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រ

កម្ពុជា

- ណែនាំព្រះវិហាពាហិរសាសនាទាំងអស់ អោយគោរពម៉ឹងម៉ាត់ តាមគម្ពីរ-ធម៌វិន័យ
របស់សានារៀង១ ខ្លួន អោយបានត្រឹមត្រូវតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា

- ណែនាំបរិស័ទគ្រប់និកាយសាសនា សាមគ្គីចូលរួមកសាងប្រទេសជាតិ មាតុភូមិ
និងអោយចេះគោរព សិទ្ធិនៃជំនឿរបស់ពលរដ្ឋ

- ពិនិត្យ និងលើកយោបល់ លើសំណើរសុំការអនុញ្ញាតអោយបើកវិហារនៃសាសនាផ្សេង១
ឬបិទសកម្ម ភាពព្រះវិហារនោះ បើពិនិត្យឃើញថាមិនគោរពតាមលក្ខន្តិកៈរបស់ខ្លួន
ធ្វើអោយប៉ះពាល់សណ្តាប់ធ្នាប់ សាធារណៈ និងច្បាប់របស់រដ្ឋ

- គ្រប់គ្រងស្ថិតិព្រះវិហារ-ទីស្នាក់ការថ្វាយបង្គំ និងបរិស័ទ ផ្នែកពាហិរសាសនា

- ពិនិត្យ និងលើកយោបល់លើសំណើរសុំការសាងសង់ និងសំណង់ព្រះវិហារ ឬការផ្លាស់ប្តូរទីកន្លែង

- លើកយោបល់លើការសុំពន្យារទិដ្ឋាការស្នាក់នៅរបស់សាសនិកបរទេស

- ពិនិត្យ និងរៀបចំឯកសារពាក់ព័ន្ធ និងការតែងតាំងមេដឹកនាំនៃសាសនាឥស្លាម អ៊ីម៉ាំ( ហាគីម) តួននៃ សាសនាឥស្លាម

- រៀបចំកិច្ចព្រមព្រៀង សហប្រតិបត្តិការអន្តរជាតិ ខាងវិស័យសាសនាផ្សេងៗ

- ធ្វើអធិការកិច្ចសាសនាគ្រប់ព្រះវិហារ

**មាត្រា៨:** នាយកដ្ឋានស្រាវជ្រាវ អប់រំ ផ្សព្វផ្សាយធម្មទេសនា ទទួលបន្ទុក :

- ស្រាវជ្រាវគម្ពីរដីកា និងដកស្រង់ ចងក្រង សំរាប់បោះពុម្ពអប់រំដល់ពុទ្ធបរិស័ទ

- តាមដានត្រួតពិនិត្យ រាល់សមាគមពុទ្ធសាសនា

- ពិនិត្យតាមដាន និងលើកសំណើប្រគេននិងជូនគ្រឿងឥស្សរិយយស ចំពោះព្រះសង្ឃ និងបរិស័ទ ដែល មានសទ្ធាជ្រះថ្លាបរិច្ចាគបច្ច័យក្នុងការសាងសង់វត្តអារាមឬគ្រឹះស្ថានសាធារណៈ

- ធ្វើកិច្ចព្រមព្រៀងនានា ស្ដីអំពីទំនាក់ទំនងសាសនា ការផ្លាស់ប្ដូរបទពិសោធន៍ និងស្វែងរកអាហារូប ករណ៏ប្រគេនព្រះសង្ឃ

- ស្រាវជ្រាវ និងតាមដានរាល់អធិករណ៏ក្នុងព្រះពុទ្ធសាសនា ដោយសហការជាមួយខុទ្ទកាល័យសម្ដេច ព្រះសង្ឃ ដើម្បីដោះស្រាយ

- ពិនិត្យ កែសម្រួលអត្ថបទ និងចាត់ចែងធម្មទេសនា ដើម្បីផ្សាយតាមវិទ្យុ និងទូរទស្សន៍

- សិក្សា ស្រាវជ្រាវ និងណែនាំអំពីការធ្វើបុណ្យ ការថែរក្សាបេតិកភណ្ឌរបស់វត្ត

- ត្រួតពិនិត្យរាល់សកម្មភាពរបស់អង្គភាពពុទ្ធសាសនាឬសមាគមព្រះពុទ្ធសាសនា។

## ជំពូក៤

# នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា៩:** នាយកដ្ឋានរដ្ឋបានល និងហិរញ្ញវត្ថុ ទទួលបន្ទុក :

ក/ ក្នុងវិស័យរដ្ឋបាលទូទៅ និងសរុប :

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាព មូលដ្ឋានក្រោមឱវាទ

- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង

- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល

- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង

ខ/ ក្នុងវិស័យគ្រប់គ្រងបុគ្គលិក :

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការ ដ្ឋានមុខងារសាធារណៈ

- រៀបចំលិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព

- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក

- រៀបចំគោលនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ និងអនុវត្តនយោបាយនោះ

- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

- គ្រប់គ្រងការងារសង្គមរបស់ក្រសួង។

គ/ ក្នុងវិស័យគ្រប់គ្រងសម្ភារៈ និងបរិក្ខារ ៈ

- ប្រមូលផ្តុំតម្រូវការធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង

- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ

- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែង ចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់

- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត ក្រុងនានា

- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ

- ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី

- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ។

ឃ/ ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ ៈ

- លើកគំរោងថវិកាក្រសួង និងតាមដានវំលឹកពីការប្រតិបត្តិ

- ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ

- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា

- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស

- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង

- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

## ជំពូកទី៥

## វិស័យពុទ្ធិកសិក្សា

**មាត្រា១០:** នាយកដ្ឋានពុទ្ធិកសិក្សា ទទួលបន្ទុក :

- ពិនិត្យ និងត្រួតត្រាលើការសិក្សាធម្មវិន័យ ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សា ពុទ្ធិកឧត្តមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា

- ត្រួតពិនិត្យ និងតាមដានដំណើរប្រព្រឹត្តទៅនៃគ្រឹះស្ថានពុទ្ធិកសិក្សា

- ណែនាំ និងផ្តល់យោបល់ចំពោះគ្រប់ភារកិច្ចដែលទាក់ទងនឹងពុទ្ធិកសិក្សា

- រៀបចំជ្រើសរើស បណ្តុះបណ្តាល និងធ្វើវិក្រិតការគ្រូបង្រៀនពុទ្ធិកសិក្សា ដោយទំនាក់ទំនងជាមួយ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

- រៀបចំការប្រឡងយកសញ្ញាប័ត្រ និងការប្រឡងប្រជែងនានា នៅគ្រប់ភូមិសិក្សានៃពុទ្ធិកសិក្សាដោយ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ លើផ្នែកការងារបច្ចេកទេសសិក្សា កម្មវិធីសិក្សាចំណេះទូទៅ បន្ថែមលើការបង្រៀនភាសាបាលី និងសំស្ក្រឹត និងមុខវិជ្ជាពុទ្ធសាសនា

- ចងក្រង និងផ្សព្វផ្សាយទស្សនាវដ្តីពុទ្ធិកសិក្សា ។

**មាត្រា១១:** ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានឋានៈស្មើនាយកដ្ឋាន ទទួលបន្ទុក :

- បណ្តុះបណ្តាលសមណសិស្ស និងសិស្សពុទ្ធិកមធ្យមសិក្សាកំរិត ២ និងពុទ្ធិកឧត្តមសិក្សា។

## ជំពូកទី៦

## ពុទ្ធសាសនបណ្ឌិត្យ

**មាត្រា១២:** ពុទ្ធសាសនាបណ្ឌិត្យមានឋានៈស្មើនាយកដ្ឋាន ទទួលបន្ទុក :

- ដឹកនាំការងារក្រុមជំនុំព្រះត្រៃបិដក

- ដឹកនាំការងារក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

- ដឹកនាំកាងារស្រាវជ្រាវទ្រឹស្តីសាសនា សាសនាប្រៀបធៀប និងបណ្ណាល័យសាខានៅតាមវត្តមួយចំនួន នៃខេត្ត ក្រុង

- ពិនិត្យ និងបោះពុម្ពស្នាដៃចាស់ៗ និងស្នាដៃថ្មី ដែលសមស្រប

- ត្រួតពិនិត្យសៀវភៅធម៌ និងសៀវភៅដែលទាក់ទងនឹងវិស័យសាសនា

- ផ្សព្វផ្សាយខ្លឹមសារអត្ថបទសាសនា អក្សរសាស្ត្រ ឧទ្ទេសកថា និងសិក្ខាសាលា

- ធ្វើសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យការងាររបស់ពុទ្ធសាសនបណ្ឌិត្យ

- ចងក្រង និងផ្សព្វផ្សាយទស្សនាវដ្តីកម្ពុជាសុរិយា។

**មាត្រា១៣:** ការរៀបចំ និងការប្រព្រឹត្តទៅនៃពុទ្ធសាសនបណ្ឌិត្យអោយទៅជាគ្រឹះស្ថានសាធារណៈ នឹង ត្រូវកំណត់ដោយអត្ថបទអនុក្រឹត្យដោយឡែក។

## ជំពូក៧

## អធិការដ្ឋាន

**មាត្រា១៤:** អធិការដ្ឋានរបស់ក្រសួងធម្មការ និងសាសនា ទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើ អង្គភាពក្រោមឱវាទក្រសួងធម្មការ និងសាសនា

- ធ្វើរបាយការណ៍ជូនរដ្ឋលេខាធិការ ពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

- ប្រតិបត្តិភារកិច្ចតាមការដែលរដ្ឋលេខាធិការបានប្រគល់ទុកចិត្ត ។

អធិការដ្ឋាន ដឹកនាំដោយអធិការមួយរូប អមដោយអធិការរងជាជំនួយការតាមការចាំបាច់ ។

## ជំពូក៨

## ខុទ្ទកាល័យរបស់ប្រធានស្ថាប័ន

**មាត្រា១៥:** ខុទ្ទកាល័យរបស់ប្រធានស្ថាប័ន ទទួលបន្ទុកការងារទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិ នៃ អនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាង លើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក៩

## អង្គភាពមូលដ្ឋាន

**មាត្រា១៦:** នៅតាមខេត្ត ក្រុងនីមួយៗ មានមន្ទីរធម្មការ និងសាសនា ខេត្ត ក្រុង ។ នៅតាមស្រុក ខណ្ឌ មានការិយាល័យធម្មការ និងសាសនា ស្រុក ខណ្ឌ ។ មន្ទីរធម្មការ និងសាសនាខេត្ត ក្រុង

និងការិយាល័យ ធម្មកា និងសាសនា ស្រុក ខណ្ឌ ទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង។

## ជំពូក១០

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា១៧:** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុង អនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតស្ថាប័ន ត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក១១

## អវសានប្បញ្ញត្តិ

**មាត្រា១៨:** ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោម នាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា។

**មាត្រា១៩:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន។

**មាត្រា២១:** អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូន

នាយករដ្ឋមន្ត្រីទី ១

សម្តេចនាយករដ្ឋមន្ត្រីទី ២

ភ្នំពេញ,ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៨

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហៀន វណ្ណារ័ត្ន

ឧបសម្ព័ន្ធរបស់អនុក្រឹត្យលេខ ១៣ អនក្រ.បក

ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

# អង្គការលេខក្រសួងធម្មការ និងសាសនា

